អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## លោក GÖRAN SLUITER ត្រូវបានតែងតាំងជាមេធាវីការពារក្តីអន្តរជាតិ

អង្គភាពគាំពារការការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានតែងតាំងលោក Göran Sluiter ជាមេធាវីអន្តរជាតិតំណាងឲ្យជនសង្ស័យមួយរូបនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរទីបី ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩។ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរទីបីគឺជាផ្នែកមួយនៃសំណុំឯកសារក្នុងសំណុំរឿង ០០៤។

លោក Göran Sluiter ជាជនជាតិហូល្លង់ ជាមេធាវីការពារក្តីឧក្រិដ្ឋកម្មនៅទីក្រុងអាមស្ទែដាម និងជាសាស្ត្រាចារ្យផ្នែកឧក្រិដ្ឋកម្មអន្តរជាតិនៅសាកលវិទ្យាល័យអាមស្ទែដាម។ លោកមានបទពិសោធន៍ជ្រៅជ្រះលើផ្នែកឧក្រិដ្ឋកម្មអន្តរជាតិ និងធ្លាប់បម្រើការជាចៅក្រមនៅក្នុងរឿងក្តីឧក្រិដ្ឋកម្មអន្តរជាតិជាច្រើននៅប្រទេសហូល្លង់ និងធ្លាប់បម្រើការនៅក្នុងក្រុមការពារក្តីនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)។

ឈ្មោះជនសង្ស័យនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរទីបីនៅតែត្រូវបានរក្សាជាការសម្ងាត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (០)១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh